អង្គការទិន្នន័យអំពីការអភិវឌ្ឍ
Open Development Cambodia Organization

YIGF CAMBODIA

# វេទិកាអភិបាលកិច្ចអ៊ីនធឺណិតសម្រាប់យុវជនកម្ពុជា ឆ្នាំ២០២៤
# យុវជនត្រួសត្រាយសង្គមឌីជីថលដែលមានភាពធន់

**កាលបរិច្ឆេទ**: ថ្ងៃទី ២-៣ វិច្ឆិកា ឆ្នាំ ២០២៤
**ទីតាំង**: រាជធានីភ្នំពេញ

## សាវតា

កាលពីឆ្នាំ២០២៣ អង្គការទិន្នន័យអំពីការអភិវឌ្ឍ ហៅកាត់ថាអូឌីស៊ី បាននាំយកវេទិកាអភិបាលកិច្ចអ៊ីនធឺណិតសម្រាប់យុវជនកម្ពុជា( YIGF ) មកផ្សព្វផ្សាយដល់យុវជនកម្ពុជាជាលើកដំបូង។ ដោយមានការទទួលស្គាល់ពីវេទិកាអភិបាលកិច្ចអ៊ីនធឺណិតរបស់អង្គការសហប្រជាជាតិ ព្រឹត្តិការណ៍ប្រចាំឆ្នាំនេះ ដើរតួជាវេទិកាបើកចំហសម្រាប់យុវជនកម្ពុជាក្នុងការចូលរួមក្នុងកិច្ចពិភាក្សាអំពីអភិបាលកិច្ចតាមអ៊ីនធឺណិត។ វេទិកានេះមានគោលបំណងផ្តល់សិទ្ធិអំណាចដល់អ្នកដឹកនាំវ័យក្មេង ដើម្បីធានាថាសំលេងរបស់គេត្រូវបានទទួលស្គាល់ក្នុងការកំណត់អនាគតឌីជីថល ។ ឆ្នាំនេះ YIGF Cambodia នឹងប្រព្រឹត្តទៅរយៈពេលពីរថ្ងៃ គឺចាប់ពីថ្ងៃទី ២-៣ ខែវិច្ឆិកា ឆ្នាំ ២០២៤។ កម្មវិធីនេះនឹងបង្ហាញពីការរួមបញ្ចូលគ្នានៃសកម្មភាពដោយផ្ទាល់ និងតាមអនឡាញ ដើម្បីបង្កើនកិច្ចពិភាក្សា និងការចូលរួមកាន់តែច្រើន។ អ្នកចូលរួមនឹងមានឱកាសពិភាក្សាអំពីបញ្ហាសំខាន់ៗទាក់ទងនឹងអភិបាលកិច្ចអ៊ីនធឺណិតជាមួយអ្នកដឹកនាំយុវជនផ្សេងទៀតមកពីប្រទេសកម្ពុជា និងវាគ្មិនដែលមានបទពិសោធន៍មកពីភាគីពាក់ព័ន្ធផ្សេងៗ។

## គោលបំណងនៃវេទិកាអភិបាលកិច្ចអ៊ីនធឺណិតសម្រាប់យុវជនកម្ពុជា

1. **បង្កើនការយល់ដឹង៖** អប់រំយុវជនអំពីបញ្ហាអភិបាលកិច្ចតាមអ៊ីនធឺណិត ដូចជា៖ ឯកជនភាពឌីជីថល សុវត្ថិភាពសាយប័រ ជម្រុញឱ្យយុវជនកម្ពុជាក្លាយជាពលរដ្ឋឌីជីថល។
2. **លើកទឹកចិត្តឱ្យមានការចូលរួម៖** ផ្តល់ឱកាសសម្រាប់យុវជនក្នុងការប្រាស្រ័យទាក់ទងជាមួយអ្នកបង្កើតគោលនយោបាយ និងអ្នកពាក់ព័ន្ធផ្សេងៗលើអភិបាលកិច្ចអ៊ីនធឺណិត។
3. **លើកកម្ពស់វិធីសាស្ត្រអ្នកពាក់ព័ន្ធច្រើន៖** ជំរុញកិច្ចសហការ និងការសន្ទនារវាងរដ្ឋាភិបាល សង្គមស៊ីវិល វិស័យឯកជន និងអ្នកជំនាញបច្ចេកទេស។

4. **ជានាសុវត្ថិភាព និងការប្រើប្រាស់អ៊ីនធឺណិតប្រកបដោយបរិយាប័ន៖** ផ្តល់អំណាចដល់យុវជនក្នុងការបញ្ចេញមតិ និងបង្ហាញក្តីកង្វល់របស់ពួកគេទាក់ទងនឹងបញ្ហាដែលទាក់ទងទៅនឹងអ៊ីនធឺណិត ជាពិសេសក្នុងការធានានូវតម្លាភាព និងគណនេយ្យភាព។

## អ្នកចូលរួម

វេទិកាយុវជន និងអភិបាលកិច្ចអ៊ីនធឺណិតនៅកម្ពុជានឹងប្រមូលផ្តុំអ្នកចូលរួមយ៉ាងតិច ២០០នាក់ មកពីមជ្ឈដ្ឋានផ្សេងៗគ្នា រួមទាំងអ្នកបង្កើតគោលនយោបាយ ក្រុមយុវជនជនជាតិដើមភាគតិច ជនពិការ ស្ត្រី ក្រុមអ្នកស្រលាញ់ភេទដូចគ្នា (LGBTQI+)។

## អ្នករៀបចំ

**អង្គការទិន្នន័យអំពីការអភិវឌ្ឍ (អូឌីស៊ី)** គឺជាវេទិកាទិន្នន័យបើកទូលាយឈានមុខគេក្នុងប្រទេសកម្ពុជា ដែលបង្កើតទិន្នន័យ និងព័ត៌មានបច្ចុប្បន្នភាព និងគួរឱ្យទុកចិត្តអំពីបញ្ហាសេដ្ឋកិច្ចសង្គម និងបរិស្ថាន បង្ហាញជាសាធារណៈក្នុងទម្រង់ជា "វេទិកាតែមួយ" ។ អង្គការអូឌីស៊ី លើកកម្ពស់ការប្រើប្រាស់ទិន្នន័យត្រឹមត្រូវសម្រាប់ដំណើរការធ្វើសេចក្តីសម្រេចចិត្តផ្អែកលើភស្តុតាង និងតម្លាភាព ឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយចីរភាពរបស់ប្រទេស។ អស់រយៈពេលដប់ឆ្នាំកន្លងមកនេះ អង្គការអូឌីស៊ីបានធ្វើការយ៉ាងសកម្ម ដើម្បីបង្កើនបរិមាណទិន្នន័យសាធារណៈ លើកកម្ពស់ការយល់ដឹងជាសាធារណៈ និងកសាងសមត្ថភាពរបស់អ្នកពាក់ព័ន្ធ។ អង្គការ អូឌីស៊ីប្រើប្រាស់ជំនាញរបស់ខ្លួនក្នុងវិស័យទិន្នន័យ និងបច្ចេកវិទ្យាទំនាក់ទំនងព័ត៌មាន (ICT) ការធ្វើផែនទី និង GIS សុវត្ថិភាពឌីជីថល និងការស្រាវជ្រាវ ដើម្បីចងក្រង វិភាគ និងផ្សព្វផ្សាយព័ត៌មានជាទម្រង់ឌីជីថលដែលងាយស្រួលប្រើ និងអាចចូលប្រើបាន។ សម្ភារៈដែលមាននៅលើវេទិកាអនឡាញរបស់អង្គការអូឌីស៊ី រួមមានសំណុំទិន្នន័យ ទំព័រប្រធានបទព័ត៌មាន ផែនទីអន្តរកម្ម ព័ត៌មាន និងឯកសារច្បាប់ ក្នុងចំណោមឯកសារផ្សេងៗទៀត។ អង្គការអូឌីស៊ី មិនផ្សព្វផ្សាយនូវទស្សនៈ របៀបវារៈ ឬការលំអៀងណាមួយ ក្រៅពីការផ្តល់ព័ត៌មានសត្យានុម័ត និងអំពីការអភិវឌ្ឍនៅប្រទេសកម្ពុជានោះទេ។

| (ថ្ងៃទី១) នៃ YIGF Cambodia ឆ្នាំ២០២៤ - ថ្ងៃសៅរ៍ ទី២ ខែវិច្ឆិកា ឆ្នាំ២០២៤ | |
|---|---|
| **ពេលវេលា** | **សកម្មភាព** |
| ០៧:៣០-០៨:០០<br>(៣០ នាទី) | **ការមកដល់ និងការចុះឈ្មោះ** |
| ០៨:០០-០៨:០៥<br>(៥ នាទី) | **ការគោរពភ្លេងជាតិនៃព្រះរាជាណាចក្រកម្ពុជា** |
| ០៨:០៥-០៨:១០<br>(៥ នាទី) | **មតិស្វាគមន៍**<br>តំណាងគណៈកម្មការយុវជនវេទិកាអភិបាលកិច្ចអ៊ីនធឺណិតសម្រាប់យុវជន |
| ០៨:១០-០៨:២០<br>(១០ នាទី) | **Remarks by Diamond Sponsor**<br>***Sponsor Name– Organization*** |
| ០៨:២០-០៨:៣០ | **Remarks by Gold Sponsor**<br>*Sponsor Name– Organization* |

Open Development Cambodia Organization

YIGF CAMBODIA

| | |
|---|---|
| (១០ នាទី) | |
| ០៨:៣០-០៨:៤០<br><br>(១០ នាទី) | សុន្ទរកថាស្វាគមន៍<br><br>លោក ធី ទ្រី នាយកប្រតិបត្តិនៃអង្គការទិន្នន័យអំពីការអភិវឌ្ឍ |
| ០៨:៤០-០៨:៥០<br><br>(១០ នាទី) | សុន្ទរកថាបើកកម្មវិធី<br><br>តំណាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| ០៨:៥០-០៩:០០<br><br>(១០ នាទី) | *តើអ្វីជាវេទិកាអភិបាលកិច្ចអ៊ីនធឺណិត?*<br><br>*ក្រុមការងារ* ***UNDESA***<br><br>***Keynote: Internet Governance by NRIs***<br><br>*Anja Gengo– UN Department of Economic and Social Affairs (UNDESA)* |
| ០៩:០០-១០:០០<br><br>(១ ម៉ោង) | ***កិច្ចពិភាក្សាស្តីពី ភាពធន់នឹងសន្តិសុខសាយប័រ***<br><br>*Speaker1, Speaker2, Speaker3, Speaker ៤* |
| *១០:០០-១០:១៥*<br><br>*(១៥ នាទី)* | សំរាកពិសាអាហារសម្រន់ |

<table>
<tr><td>១០:១៥-១០:៤៥<br><br>(៣០ នាទី)</td><td>Topic Presentation #1<br>Speaker</td><td>Topic Presentation #2<br>Speaker</td></tr>
<tr><td>១០:៤៥-១១:២៥<br><br>(៤០ នាទី)</td><td>Topic Presentation #3<br>Speaker</td><td rowspan="2">Panel Discussion or<br>Multi-Stakeholder Meeting<br>ODC</td></tr>
<tr><td>11:25 – 12:00 (35 mins)<br><br>១១:២៥-១២:០០<br><br>(៤០ នាទី)</td><td>Topic Presentation #4<br>Speaker</td></tr>
<tr><td>១២:០០-១៣:០០<br>(៦០នាទី)</td><td colspan="2">សម្រាកពិសាអាហារថ្ងៃត្រង់</td></tr>
<tr><td>១៣:០០-១៤:៣០<br><br>(៩០ នាទី)</td><td colspan="2">ការជជែកដេញដោលជុំចុងក្រោយ<br><br>ការពិភាក្សា៖ ៥០ នាទី។<br><br>សំណួរ-ចម្លើយ៖ ១០ នាទី។<br><br>ការពិភាក្សារបស់ចៅក្រម៖ ១០ នាទី។<br><br>Buffer: 10 នាទី។<br><br>ការប្រកាសក្រុមជ័យលាភី</td></tr>
</table>

អង្គការទិន្នន័យអំពីការអភិវឌ្ឍ Open Development Cambodia Organization

YIGF CAMBODIA

| | | |
|---|---|---|
| *១៤:៣០-១៤:៤៥*<br>*(១៥ នាទី)* | *សម្រាកពិសាអាហារសម្រន់* | |
| ១៤:៤៥-១៥:២៥<br>(*៤០ នាទី*) | **Topic Presentation #5**<br>*Speaker* | **Topic Presentation #6**<br>*Speaker* |
| ១៥:២៥-១៦:៤៥<br>(៨០ *នាទី*) | *ប្រព័ន្ធអេកូនៃអភិបាលកិច្ចអ៊ីនធឺណិត និងហេដ្ឋារចនាសម្ព័ន្ធអ៊ីនធឺណិត*<br>*វាគ្មិន*<br>*កិច្ចសន្ទនារបស់យុវជន លើប្រធានបទ* ***Overarching Theme*** *ភាគ១*<br>*បំបែកអ្នកចូលរួមជាក្រុមតូចៗ* | |
| ១៦:៤៥-១៧:០០<br>(១៥ *នាទី*) | ***ការសង្ខេបថ្ងៃទី១ និងរូបថតជាក្រុម*** | |

| (ថ្ងៃទី២) នៃ YIGF Cambodia ឆ្នាំ២០២៤ - ថ្ងៃអាទិត្យ ទី៣ ខែវិច្ឆិកា ឆ្នាំ២០២៤ | |
|---|---|
| **ពេលវេលា** | **សកម្មភាព** |
| ០៧:៣០-០៨:០០<br>(១៥ នាទី) | **ការមកដល់ និងការចុះឈ្មោះ** |
| ០៨:០០-០៨:១០<br>(១០ នាទី) | **ការផ្ដុះបញ្ចាំង** |
| ០៨:១០-០៩:០០<br>(៥០ នាទី) | **Youth Dialogue on the Overarching Theme Part 2**<br>*Participants Presenting*<br><br>***Youth Dialogue on the Overarching Theme Part 2***<br>*Participants Presenting*<br><br>*កិច្ចសន្ទនារបស់យុវជន លើប្រធានបទ **Overarching Theme** ភាគ២*<br>*អ្នកចូលរួមធ្វើបទបង្ហាញ* |
| ០៩:០០-១០:០០<br>(១ ម៉ោង) | **Panel Discussion on AI and Us**<br>*Speaker1, Speaker2, Speaker3, Speaker4* |

អង្គការទិន្នន័យអំពីការអភិវឌ្ឍ
Open Development Cambodia Organization

YIGF CAMBODIA

| | | |
|---|---|---|
| | *កិច្ចពិភាក្សាស្តីពី បញ្ញាសិប្បនិម្មិត និងពួកយើង*<br>*Speaker1, Speaker2, Speaker3, Speaker ៤* | |
| *១០:០០-១០:១៥*<br>*(១៥ នាទី)* | សម្រាកពិសាអាហារសម្រន់ | |
| ១០:១៥-១០:៥៥<br>(៤០ នាទី) | **Topic Presentation #5**<br>*Speaker* | **Topic Presentation #6**<br>*Speaker* |
| ១០:៥៥-១១:៥៥<br>(១ ម៉ោង) | **កិច្ចពិភាក្សាស្តីពី ការគ្រប់គ្រងទិន្នន័យប្រកបដោយនិរន្តរភាព**<br>**Speaker1, Speaker2, Speaker3, Speaker ៤** | |
| *១២:០០-១៣:០០*<br>*(១ ម៉ោង)* | *សម្រាកពិសាអាហារថ្ងៃត្រង់* | |
| ១៣:០០-១៥:០០<br>(២ ម៉ោង) | សន្និសិទអភិបាលកិច្ចអ៊ីនធឺណិតដែលមានភាគីពាក់ព័ន្ធជាច្រើនចូលរួម<br>***Participants*** | |
| *១៥:០០-១៥:១៥*<br>*(១៥នាទី)* | *សម្រាកពិសាអាហារសម្រន់* | |

| | |
|---|---|
| ១៥:១៥-១៦:១៥<br><br>(១ ម៉ោង) | **Townhall**<br>*Participants & OCs* |
| ១៥:១៥-១៦:៤៥<br><br>(៣០ នាទី) | **ដំណើរឆ្ពោះទៅមុខ**<br>*OC* |
| ១៦:៤៥-១៦:៥៥<br><br>(១០ នាទី) | **Closing Remark**<br>*ODC & AC* |
| ១៦:៥៥ – ១៧:០០<br>(៥ នាទី) | **Event Wrap & Group Photo**<br>*Participants and OCs* |

ចំណាំថា៖របៀបវារៈនៃវេទិកាអភិបាលកិច្ចអ៊ីនធឺណិតសម្រាប់យុវជនកម្ពុជាឆ្នាំ២០២៤ អាចនិងមានការកែសម្រួលក្នុងករណីចាំបាច់។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងទៅកាន់ លោកសុខ ហាំងឃាង  មន្រ្តីផ្នែកទំនាក់ទំនងតាមទូរស័ព្ទ ឬ Telegram ៖ ០៧៨ ៦៦៩ ៤៣៩ ។